ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

# ដំណាំដំឡូងមី








ផលិតដោយ: នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឆ្នាំ២០១៦

# សៀវភៅ

# ស្តីពី

# ដំណាំដំឡូងមី

## រៀបចំដោយ

## នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

បោះពុម្ពលើកទី១ ចំនួន ២០០០ ច្បាប់

ផលិតដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រក្សាសិទ្ធដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# សមាសភាពចូលរួមចំណែកផលិតសៀវភៅ
# ស្តីពីដំណាំដំឡូងមី

## I. ទីប្រឹក្សាផ្តល់យោបល់:

១. បណ្ឌិត **ម៉ាក់ សឿន** អគ្គនាយកដ្ឋានកសិកម្ម

២. បណ្ឌិត **ម៉ៅ មិនា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. លោក **ប៉ែន វុទ្ធី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. លោក **គឹម ដារ៉ា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

## II. អ្នករៀបរៀង:

១. លោក **ផាន ទូច** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

## III. ក្រុមអ្នកស្រាវជ្រាវ:

១. លោក **នូ ប្រណិត** មន្ទីរកសិកម្មខេត្តបាត់ដំបង

២. លោក **វ៉ាត គឹមជាង** មន្ទីរកសិកម្មខេត្តកំពង់ធំ

## IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

១. លោក **សុភ វណ្ណា** នាយកដ្ឋានដំណាំឧស្សាហកម្ម

២. លោក **លី ចំរើន** នាយកដ្ឋានដំណាំឧស្សាហកម្ម

៣. លោក **ពេជ សុវត្ថារ៉ា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៤. លោក **ហុង ទ្រី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម





## មាតិកា ទំព័រ


**១. សេចក្ដីផ្ដើម**..........០១

**២. ស្ថានភាពទូទៅនៃដំណាំដំឡូងមី**..........០១

២.១ ដើមកំណើត និងប្រវត្តិដំណាំដំឡូងមី..........០១

២.២ ស្ថានភាពដំណាំដំឡូងមីនៅលើពិភពលោក....០២

២.៣ ស្ថានភាពដំណាំដំឡូងមីនៅកម្ពុជា..........០២

២.៤ សារៈប្រយោជន៍ដំណាំដំឡូងមី..........០២

**៣. លក្ខខណ្ឌបរិស្ថាននៃដំណាំដំឡូងមី**..........០២

៣.១ សីតុណ្ហភាព..........០២

៣.២ ពន្លឺ..........០៣

៣.៣ សំណើម..........០៣

៣.៤ តម្រូវការទឹក..........០៣

៣.៥ ដី..........០៣

**៤. លក្ខណៈរូបសាស្ត្រនៃដំណាំដំឡូងមី**..........០៤

៤.១ លក្ខណៈដើម..........០៤

៤.២ លក្ខណៈស្លឹក..........០៤

៤.៣ លក្ខណៈផ្កា..........០៤

៤.៤ លក្ខណៈផ្លែ..........០៥

៤.៥ លក្ខណៈឫស..........០៥

**៥. អំពីពូជ**..........០៥

៥.១ ការកំណត់ចំណាំពូជ..........០៥

៥.២ អាយុកាលដើមត្រូវទុកពូជ..........០៥
៥.៣ លក្ខណៈដើមពូជសមស្រប..........០៦
៥.៤ ប្រវែងនៃកំណាត់ដើមពូជត្រូវកាត់..........០៦
៥.៥ អំពីចំនួនភ្នែក..........០៦
៥.៦ ការកាត់ដើម..........០៧
៥.៧ ផលប៉ះពាល់នៃការខូចដើមពូជ..........០៧
៥.៨ ពូជសម្រាប់បរិភោគមើម..........០៩
៥.៩ ប្រភេទពូជសម្រាប់យកម្សៅ..........០៩
**៦. បច្ចេកទេសនៃការដាំដុះដំណាំដំឡូងមី..........១០**
៦.១ វិធីសាស្ត្រនៃការរៀបចំដី..........១០
៦.២ វិធីសាស្ត្រនៃការដាំដុះ..........១២
ក. ការដាំបញ្ឈៀង..........១២
ខ. ការដាំផ្ដេក..........១២
គ. ការដាំបញ្ឈរ..........១៣
ឃ. រដូវកាលដាំដុះ..........១៣
ង. ចន្លោះជួរ និងចន្លោះគុម្ព..........១៣
**៧. ការប្រើប្រាស់ជីលើដំណាំដំឡូងមី..........១៤**
**៨. ការថែទាំ..........១៤**
៨.១ ការជួយដីពូនគល់ និងបោចស្មៅ..........១៤
៨.២ ការរលួសស្លឹក..........១៥
៨.៣ ការកម្ចាត់ស្មៅ..........១៥
ក.ផលប៉ះពាល់នៃការពន្យាពេលកម្ចាត់ស្មៅ..........១៥
ខ. ពេលវេលាសមស្របក្នុងការកម្ចាត់ស្មៅ..........១៥
៨.៤ វិធីសាស្ត្រទប់ស្កាត់ការហូរច្រោះ និងសារប្រយោជន៍..........១៦
**៩.វិធានការការពារ គក្តាចង្រៃលើដំណាំដំឡូងមី..........១៦**
៩.១ វិធានការក្សេតសាស្ត្រ..........១៦
៩.២ វិធានការគីមី..........១៧
ក.ជំងឺ..........១៧
ខ.សត្វល្អិត..........២១
**១០. ការប្រមូលផល និងទុកដាក់ដំណាំដំឡូងមី..........២៦**



# ដំណាំដំឡូងមី

## ១. សេចក្តីផ្តើម

ដំណាំដំឡូងមី គឺជាប្រភេទដំណាំចំណីអាហាររបស់មនុស្សសត្វតាំងពីបុរាណកាលមកម្ល៉េះ។

ដំណាំដំឡូងមី ក្រៅអំពីមើម ត្រួយរបស់ដំឡូងគេអាចយកមកធ្វើជាបន្លែយ៉ាងប្រសើរ ដោយហេតុថាស្លឹក ដំឡូងមីក៏សម្បូរទៅដោយវីតាមីនអា ដែលអាចជួយការពារជំងឺភ្នែករបស់កុមារផងដែរ។

## ២. ស្ថានភាពទូទៅនៃដំណាំដំឡូងមី

ដំណាំដំឡូងមី មានការដាំដុះនៅលើពិភពលោកប្រមាណជាង ៩០ ប្រទេស និង ៣ទ្វីប ក្នុងនោះមានទ្វីបអាស៊ី អាមេរិក និងទ្វីបអាហ្វ្រិក។

ទ្វីបអាស៊ីមានប្រមាណ២០% ក្នុងនោះមានប្រទេស ឥណ្ឌូនេស៊ី ថៃ កម្ពុជា វៀតណាម ចិន ជាដើម។ល។

ទ្វីបអាមេរិក មានប្រមាណ ៣០% ក្នុងនោះមានប្រទេស ប្រេស៊ីល កូឡុំប៊ី ជាដើម ។ល។

ទ្វីបអាហ្វ្រិក មានប្រមាណ៥០% ក្នុងនោះមានប្រទេស នីហ្សេរីយ៉ា អង់ហ្គោឡា ម៉ាដាហ្គាសកា និងប្រទេសមួយចំនួនទៀតដែលស្ថិតនៅក្នុងទ្វីបនេះ។

### ២.១ ដើមកំណើត និងប្រវត្តិដំណាំដំឡូងមី

ដំណាំដំឡូងមី មានដើមកំណើតនៅអាមេរិកឡាទីន ដែលត្រូវបានគេដាំដុះនៅក្នុងប្រទេសប៉េរូ តាំងតែពី៤០០០ ឆ្នាំកន្លងមកហើយ និងក្នុងប្រទេសម៉ិចស៊ិកកូតាំងតែពី២០០០ឆ្នាំ កន្លងមកហើយដែរ ក្រោយមកក៏បាន

រីកសាយភាយដល់ទ្វីបអាហ្វ្រិកនិងមកកាន់អាស៊ីដោយជនជាតិអេស្ប៉ាញ នៅអំឡុងពេលដំណើរមកកាន់ប្រទេសហ្វីលីពីនរបស់ពួកគេ ហើយក៏រីកសាយភាយបន្តទៀតពាសពេញតំបន់ត្រូពិចនៃទ្វីបអាស៊ីត្រឹមសតវត្សទី១៦ ។

### ២.២ ស្ថានភាពដំណាំដំឡូងមីនៅលើពិភពលោក

នៅក្នុងឆ្នាំ២០០២ ការផលិតមើមដំឡូងមីនៅលើពិភពលោកមានចំនួនប្រមាណ ១៨៤លានតោន ហើយការផលិតបានកើនដល់ ២២៦ លានតោននៅឆ្នាំ២០០៩។ នៅក្នុងឆ្នាំ២០០២ដែរ នៅក្នុងទ្វីបអាស៊ីផលិតបានចំនួន៥៥,៥ លានតោន និង នៅក្នុងទ្វីបអាមេរិកឡាទីនផលិតបានចំនួន ៣៣,២ លានតោន។

### ២.៣ ស្ថានភាពដំណាំដំឡូងមីនៅកម្ពុជា

នៅប្រទេសកម្ពុជា ដំណាំដំឡូងមីគឺជាដំណាំមានសារសំខាន់ទី៣ បន្ទាប់ពីដំណាំស្រូវ និងពោត។ ដំណាំដំឡូងមីត្រូវបានដាំដុះនៅកម្ពុជានៅក្នុងសតវត្សទី១៩ ដែលជាទូទៅប្រជាកសិករនិយមដាំដើម្បីយកមើម ពីព្រោះដំណាំប្រភេទនេះ ងាយស្រួលដាំ និងមានភាពធន់ទ្រាំទៅនឹងភាពរាំងស្ងួត។

នៅប្រទេសកម្ពុជា តំបន់ដែលមានការដាំដុះដំណាំប្រភេទនេះច្រើនមានដូចជានៅខេត្តកំពង់ចាម បាត់ដំបង កំពង់ស្ពឺ សៀមរាប និងខេត្តកំពង់ធំ

## ៣. លក្ខខណ្ឌបរិស្ថាន នៃដំណាំដំឡូងមី

### ៣.១ សីតុណ្ហភាព

សីតុណ្ហភាពសមស្របសម្រាប់ការដុះលូតលាស់ដំណាំដំឡូងមីគឺក្នុងចន្លោះពី២៥-២៩ អង្សាសេ ។ ក៏ប៉ុន្តែដំណាំដំឡូងមីអាចធន់ទ្រាំនឹងសីតុណ្ហភាពចន្លោះពី ១៦-៣៨ អង្សាសេ ។ កាលណាសីតុណ្ហភាពទាបជាង១៦ អង្សាសេ ការដុះលូតលាស់របស់ដំឡូង ដែលដាំដោយកំណាត់ដើមត្រូវបានពន្យាពេលការពង្រីកមើម ការដុះលូតលាស់ស្លឹក និងថយចុះ

បរិមាណមើម។

### ៣.២ ពន្លឺ

ដំណាំដំឡូងមីត្រូវការពន្លឺព្រះអាទិត្យច្រើន សម្រាប់ការធ្វើរស្មីសំយោគ និងជំរុញការដុះលូតលាស់ស្លឹក ម្យ៉ាងទៀតពន្លឺបានចូលរួមយ៉ាងសកម្មក្នុងការបង្កើតជាតិអាមីដុងនៅក្នុងមើម។

### ៣.៣ សំណើម

ដំណាំដំឡូងមីមិនមែនជាប្រភេទដំណាំដែលត្រូវការសំណើមខ្ពស់ ឬជាំទឹកឡើយ ។ នៅពេលមានសំណើមខ្ពស់ ឬជាំទឹក ធ្វើឱ្យការដុះលូតលាស់ចុះខ្សោយ ដូចជា ដើមតូច ទាប ស្លឹកមានពណ៌លឿង និងជ្រុះស្លឹកជាបន្តបន្ទាប់ ពិសេសក្នុងអំឡុងពេលប្រមូលផល ធ្វើឱ្យមើមរលួយជាមូលហេតុធ្វើឱ្យទិន្នផលចុះទាប។

### ៣.៤ តម្រូវការទឹក

ដំឡូងមីដុះលូតលាស់ល្អបំផុត នៅក្នុងកម្រិតទឹកភ្លៀងប្រចាំឆ្នាំពី ៥០០ ម.ម - ៥០០០ ម.ម ។ ទឹកភ្លៀងកម្រិតនេះ អាចឱ្យដំណាំដំឡូងមីបន្តការដុះលូតលាសពេញមួយរដូវប្រាំងបានទៀត ដែលដំណាំខ្លះមិនមានភាពធន់ទ្រាំបែបនេះបាន។

### ៣.៥ ដី

ប្រភេទដីដែលសមស្រប សម្រាប់ការដុះលូតលាស់របស់ដំណាំដំឡូងមី គឺជាប្រភេទដីមានជីជាតិល្អ មិនជាំទឹក និងមានដង្ហើមខ្យល់ចេញចូលល្អ មិនមានសារធាតុពុលនៅក្នុងដី ជាប្រភេទដីល្បាប់ល្បាយខ្សាច់។ ដោយសារដំណាំដំឡូងមី ជាប្រភេទដំណាំមិនត្រូវការសំណើមខ្ពស់ ដូច្នេះការដាំដុះទាមទារនូវការរៀបដី ឱ្យមានប្រព័ន្ធបញ្ចេញបញ្ចូលទឹក និងមានជម្រៅដីជាមធ្យមពី ៥០ ស.ម ទៅ ១ ម៉ែត្រ។

# ៤. លក្ខណៈរូបសាស្ត្រ នៃដំណាំដំឡូងមី

## ៤.១ លក្ខណៈដើម



ដើមដំឡូងមីមានសណ្ឋានត្រង់ ឬកោង អាស្រ័យទៅនឹងការដុះលូតលាស់ ដើមមួយអាចបែកមែក២ ទៅ ៤ មែក និងមានដើមខ្លះក៏មិនបែកមែកដែរ។ កម្ពស់ដើម គិតជាមធ្យមអាចពី ១៥០ ស.ម-៣០០ ស.ម ពណ៌ទឹកប្រាក់លាយបៃតង ឬប្រផេះ ទំហំដើមអាចពី ៨-១២ ស.ម ដើមដំឡូងមីមានសភាពផុសស្រួយ ងាយនឹងបាក់បែក។

## ៤.២ លក្ខណៈស្លឹក



ស្លឹករបស់ដំណាំដំឡូងមី ចែកចេញជាពីប្រភេទ គឺទង ស្លឹក និងផ្ទៃស្លឹក មានសណ្ឋានស្តើង និងឆែក ឬជាសន្លឹកតូចៗមានពី៣-៩សន្លឹក ដោយចុងស្លឹកមានទម្រង់ស្រួចមានពណ៌បៃតងចាស់ ហើយស្លឹកទុំមានសភាពរលោង។

## ៤. ៣ លក្ខណៈផ្កា



ផ្កាដំឡូងមីមានលក្ខណៈទ្វេភេទ ដុះចេញពីក្នុងដើមតែមួយ ជាមួយគ្នា មានលក្ខណៈជាចង្កោម ឬជាកញ្ចុំ មានប្រវែង២០ស.ម មានផ្កាញីប្រមាណពី ៣-២០ ផ្កាឈ្មោលមានប្រមាណពី៥០-២០០។

### ៤.៤ លក្ខណៈផ្លែ



ផ្លែដំឡូងមី មានរាងមូល មាន៣ថត ពេលទុំសម្បកមានទម្រង់ដូចស្លាបមានចំនួន៦ បន្ទាប់ពីអាយុបាន ៧៥-៩០ ថ្ងៃក្រោយពេលចេញផ្កា គ្រាប់មានបណ្តោយប្រវែង ១០០ ម.ម ទទឹងប្រវែង៦ ម.ម និងមានកម្រាស់៤ ម.ម មានពណ៌បៃតងខ្ចី ឬចាស់ សម្បកគ្រាប់មានពណ៌ភ្លឺរលោង ហើយនឹងគ្រាប់មានពណ៌ក្រម៉ៅ

### ៤.៥ លក្ខណៈឫស



ដំឡូងមី មានឫស ឬ មើមជាសរសៃ ឫសដុះចេញពីផ្នែកនៃកំណាត់ដើម។ ឫសចាប់ផ្តើមរីកលូតលាស់ ក្លាយជាមើម នៅពេលដាំរយៈពេល១ខែកន្លះ ទៅ២ខែ។ មើមមានទំហំពី៥ស.ម-២០ ស.ម មានរាងមូលទ្រវែង សំបកមានពណ៌ដី ឬត្នោតខ្ចី សាច់មើមមានពណ៌ស។

## ៥. អំពីពូជ

### ៥.១ កំណាត់ចំណាំ លើពូជ

- អាត្រាដំណុះអាស្រ័យទៅលើប្រភេទរបស់ពូជ
- ដើមពូជពេលណាទុកវាលើសពី ១៥ ថ្ងៃទើបដាំធ្វើឱ្យអត្រាដំណុះធ្លាក់ចុះ

### ៥.២ អំពីអាយុរបស់ដើមត្រូវទុកពូជ

- ដើមពូជដែលល្អត្រូវមានអាយុពី ៨-១៨ ខែ
- ដើមពូជដែលមានអាយុលើសពី១៨ ខែ ធ្វើឱ្យមានជាតិឈើខ្ពស់

អត្រាដំណុះចុះខ្សោយ ពន្លកដុះចេញមកមានសុខភាពមិនល្អ

- ដើមខ្ចី ងាយទទួលរងការបំផ្លាញពីសត្វល្អិត និង ភ្នាក់ងារចម្លងជំងឺ ឆាប់ខ្សោះជាតិទឹក ទុកមិនបានយូរ និងងាយរលួយ ។



### ៥.៣ លក្ខណៈដើមពូជសមស្រប

- មានអាយុកាលយ៉ាងច្រើនត្រឹម១៨ ខែ
- ពូជដែលមានសន្ទុះការលូតលាស់ខ្លាំង
- ចំពោះពូជដែលមានអាយុ៨ ខែ ត្រូវកាត់យកតែផ្នែកកណ្តាល

### ៥.៤ ប្រវែងនៃកំណាត់ដើមពូជត្រូវកាត់

- ជាការសមស្រប គឺត្រឹម ២០-២៥ ស.ម តែក៏អាស្រ័យទៅតាមប្រភេទពូជផងដែរ ដោយហេតុថាពូជខ្លះមានភ្នែកញឹក និងពូជខ្លះទៀតមានភ្នែករង្វើល។
- ការកាត់កំណាត់ដើមពូជវែងពេកធ្វើឱ្យប្រើប្រាស់ពូជច្រើននិងពិបាកក្នុងដឹកជញ្ជូន

### ៥.៥ អំពីចំនួនភ្នែក

- ជាការប្រសើរប្រវែងកំណាត់កង់ដែលត្រូវកាត់ អាចមានចំនួន ៥

ទៅ ៧ ភ្នែកក្នុង១កំណាត់ (អាស្រ័យតាមប្រភេទពូជ)

- កំណាត់កង់ដែលមានត្រឹម ១-៣ ភ្នែក ធ្វើឱ្យឫសដុះមិនល្អ ឆាប់ខ្សោះជាតិទឹក
- បង្កភាពងាយស្រួលឱ្យភ្នាក់ងារបង្ករោគក្នុងការចម្លងជំងឺ

## ៥.៦ ការកាត់ដើម

- ត្រូវកាត់នឹងកាំបិទ ឬរណារមុត
- ការកាត់ត្រូវមានការប្រុងប្រយ័ត្ន ធ្វើយ៉ាងណាកុំឱ្យខ្ទាំសំបក និងសាច់ដើមពូជរបូស ។





## ៥.៧ ផលប៉ះពាល់បណ្តាលមកពីការខូចលក្ខណៈរូបនៃកំណាត់កង់

- ធ្វើឱ្យថយចុះគុណភាពពូជ
- ពេលកាត់ ទុកដាក់ និងដឹកជញ្ជូនត្រូវបញ្ចៀសពីការបែកបាក់ ឬរលាត់
- ស្នាមបែកបាក់ ឬដាច់រលាត់ ជាហេតុធ្វើឱ្យកំណាត់ពូជងាយរលួយនៅក្រោយពេលដាំ ដោយសារភ្នាក់ងារបង្ករោគ អាចកកើតនៅតាមស្នាមបាក់បែក ឬដាច់រលាត់នោះ។

## ប្រភពពូជដំឡូងមី

- ពូជហូបមើម
- ពូជសម្រាប់យកម្សៅ
- ពូជជាប្រភេទរុក្ខជាតិលម្អ

**ពូជដំឡូងមីដែលបានដាំក្នុងកសិដ្ឋានផលិតពូជដំណាំតំបន់ដីខ្ពស់ចម្ការលើ**

| ល.រ | ឈ្មោះ | ប្រភព |
|---|---|---|
| ១ | Rayong 1 | ប្រទេសថៃ |
| ២ | Rayong 5 | ប្រទេសថៃ |
| ៣ | Rayong 7 | ប្រទេសថៃ |
| ៤ | Rayong 9 | ប្រទេសថៃ |
| ៥ | Rayong 60 | ប្រទេសថៃ |
| ៦ | Rayong 72 | ប្រទេសថៃ |
| ៧ | Rayong 90 | ប្រទេសថៃ |
| ៨ | Huay Bong 60 | ប្រទេសថៃ |
| ៩ | OMR36-31-1 | ប្រទេសចិន |
| ១០ | GR891 | ប្រទេសចិន |
| ១១ | Nep | ប្រទេសវៀតណាម |
| ១២ | SC9 | ប្រទេសចិន |
| ១៣ | SC5 | ប្រទេសចិន |
| ១៤ | SC8 | ប្រទេសចិន |
| ១៥ | SC201 | ប្រទេសចិន |
| ១៦ | Batrang | ប្រទេសវៀតណាម |

| | | |
|---|---|---|
| ១៧ | Nanzhi199 | ប្រទេសចិន |
| ១៨ | Damlong Slektouch | កម្ពុជា |
| ១៩ | KM98-1 | ប្រទេសវៀតណាម |
| ២០ | KU50 | ប្រទេសថៃ |
| ២១ | V2 | ប្រទេសវៀតណាម |
| ២២ | Damlong Kor | កម្ពុជា |

## ៥.៨ ពូជសម្រាប់បរិភោគមើម

ពូជនេះមើមរបស់វាមានសភាពម៉ដ្ឋ រសជាតិផ្អែមច្រើនជាងល្វីង ហើយជាពូជដែលធន់ទ្រាំទៅនឹងភាពរាំងស្ងួត មានរយៈពេលលូតលាស់ពី ៨ ឬ ១២ ខែ ។

## ៥.៩ ប្រភេទពូជសម្រាប់យកម្សៅ

ពូជនេះ មើមរបស់វាសាច់មានសភាពគ្រើម មានរស់ជាតិល្វីង រយៈពេលលូតលាស់វែងជាងប្រភេទពូជបរិភោគមើម ។





*ពូជសម្រាប់បរិភោគមើម*




*ពូជដំឡូងសម្រាប់យកម្សៅ*

## ៦. បច្ចេកទេសនៃការដាំដុះ ដំណាំដំឡូងមី

### ៦.១ វិធីសាស្ត្រនៃការរៀបចំដី

ត្រូវកាប់ ឬ ភ្ជួរដីឱ្យបានជម្រៅប្រហែលពី ២០-៣០ ស.ម  ភ្ជួរឱ្យបាន ២ ទៅ ៣ ដងដើម្បីឱ្យដីផុសល្អ បន្ទាប់មកត្រូវរើសយកស្មៅចេញឱ្យស្អាត និងត្រូវហាលដីឱ្យបានស្ងួតល្អ ។




**គេអាចដាំដំឡូងមីបានច្រើនរបៀប ៖**

**របៀបទី ១ :**

កាប់ជារណ្តៅទំហំកន្លះម៉ែត្របួនជ្រុងនិងជម្រៅកន្លះម៉ែត្រហើយក្នុង

រណ្តៅត្រូវដាក់ជីកំប៉ុស្ត ឬជីធម្មជាតិរួចច្របល់នឹងដីបាតរណ្តៅ។ បន្ទាប់មកយកដើមដែលកាប់ខ្លីៗទៅកប់ក្នុងរណ្តៅរាងបញ្ឈរត្រង់ ឬ រាងទ្រេត ឬបញ្ឆិតបន្តិច ឬកប់ដីបាតតែម្តង ។ គេច្រើនអនុវត្តរបៀបនេះនៅរដូវប្រាំង ។





### របៀបទី ២ :

លើកជារងដែលមានទទឹង១ម៉ែត្រ និងកម្រាស់ពី២០ - ៣០ ស.ម ។ បន្ទាប់មកកាប់ជារណ្តៅតូចលើរង រួចកប់ដើមដំឡូងតាមរបៀបដាំទី១អញ្ចឹងដែរ។ ការដាំដំឡូងមីត្រូវទុកចន្លោះជួរ ឬរង ៩០-១០០ ស.ម និងចន្លោះគុម្ពពី ៤០-៩០ ស.ម អាស្រ័យទៅតាមប្រភេទដីមានជីជាតិឬខ្សោះ។ក្រោយពេលដាំរួច ត្រូវស្រោចទឹក រហូតដល់ដុះពន្លក។ ដំណាក់ការនេះដំឡូងមីពុំសូវត្រូវការទឹកច្រើនពេកទេ ។





## ៦.២. វិធីសាស្ត្រនៃការដាំដុះ :

### ក. ការដាំបញ្ឈរ :

ការដាំតាមវិធីនេះ យើងត្រូវដាក់កំណាត់ដំឡូងរាងបញ្ឈរដែលមានមុំពី ២០-៤៥ ដឺក្រេ ។ ជាទូទៅការដាំយើងត្រូវកប់ដើមដំឡូងឈើផ្នែកខាងក្រោមនៃដងដើមទៅក្នុងដីឱ្យជ្រៅ ហើយយើងក៏អាចរោយដីកប់តែម្តង ឬក៏កប់ដោយទុកដើមឱ្យនៅផុតពីដីបន្តិច ។



### ខ. ការដាំផ្តេក :

ការដាំរបៀបនេះអ្នកត្រូវដាក់ដើមដំឡូងផ្តេកនៅក្នុងជួររងតែម្តង រួចហើយរោយដីកប់ពីលើក្នុងជម្រៅពី ៥-១០ សង់ទីម៉ែត្រ ។



### គ. ការដាំបញ្ឈរ :

ការដាំរបៀបនេះយើងត្រូវដាក់ដើមដំឡូងបញ្ឈរទៅក្នុងដី រួចហើយត្រូវកប់ ផ្នែកចាស់នៃដើមទៅក្នុងដី ហើយទុកផ្នែកខាងចុង ឱ្យនៅផុតពីដីបន្តិច (២ភាគនៅក្នុងដី និង២ភាគនៅលើដី។



### ឃ. រដូវកាលដាំដុះ

ដំណាំដំឡូងមីអាចដាំបានទាំងរដូវប្រាំង និងវស្សា។ នៅរដូវវស្សាអាចចាប់ផ្តើមដាំពីខែឧសភា -មិថុនា និងប្រាំងចាប់ពីខែ វិច្ឆិកា- ធ្នូ បន្ទាប់ពីទឹកទន្លេរចាប់ផ្តើមស្រក។

### ង. ចន្លោះជួរ និងចន្លោះគុម្ព

| ចន្លោះពីជួរ១ទៅជួរ១ | ចន្លោះពីដើម១ទៅដើម១ | ចំនួនដើម |
|---|---|---|
| ៩០ ស.ម | ៦០ ស.ម | ១៨.០០០ដើម/ហ.ត |
| ៩០ ស.ម | ៩០ ស.ម | ១២.០០០ដើម/ហ.ត |
| ៩០ ស.ម | ១២០ ស.ម | ៩.០០០ដើម/ហ.ត |

## ៧. ការប្រើប្រាស់ជីលើដំណាំដំឡូងមី

ដំឡូងមីត្រូវការជីជាតិប៉ូតាស្យូមច្រើន ដើម្បីបង្កើនជាតិម្សៅ របស់មើម ។ ការដាក់ជីហួសកម្រិត អាចបណ្ដាលឱ្យអ្នកដាំខាតបង់ថវិកា កម្លាំងពលកម្ម ព្រោះវាធ្វើឱ្យដើមដងដុះលូតលាស់ល្អពេក តែមានមើមស្រាលរីឯទិន្នផលក៏ថយចុះដែរ ។

ការប្រើប្រាស់ជីលាមកសត្វដាក់ទ្រាប់បាត គឺជាការល្អសម្រាប់ដំណាំដំឡូងមី កម្រិតជីត្រូវប្រើពី ៦ ទៅ ៧ តោន/ហិកតា និងជីគីមី ១៥.១៥.១៥ ក្នុងកម្រិតសមស្របទ្រាបបាតបន្ថែម។ រីឯការដាក់ជីសម្រាប់បំប៉ន គេអាចដាក់ជាលើកទី ១ ក្រោយដាំបានអាយុ ១ ខែ បន្ទាប់ពីដាំ និងលើកទី ២នៅពេលដំឡូងអាយុបាន ៣ ខែក្រោយដាំដោយប្រើជីអ៊ុយរ៉េ ។



*ជីសរីរាង្គ និងគីមី(ប៉ូតាស្យូម)*



*ជីកំប៉ុស្ត*

## ៨. ការថែទាំ ៖

### ៨.១ ការជ្រួយដីពូនគល់ និងបោចស្មៅ :

ត្រូវជំរះស្មៅជ្រួយដីឱ្យបានញឹកញាប់ពេលដើមដំឡូងមីនៅតូច។ត្រូវពូនគល់ក្រោយពេលដាំរយៈពេល២-៣ ខែដើម្បីជួយទប់ដើម កុំឱ្យដួលរលំ ហើយផ្ដល់មើមធំល្អ។ ការងារនេះសំខាន់ណាស់គឺធ្វើឱ្យ ដីធូរខ្យល់ចេញចូល

បានល្អ ងាយស្រួលក្នុងការចាក់ឫសធ្វើឱ្យដើមដងរឹងមាំ ។

### ៨.២ ការលួសស្លឹក :

គេអាចលួសស្លឹកខាងក្រោមចេញខ្លះ នៅពេលដែលវាមានកម្ពស់ពី ៨០ ទៅ ១០០ ស.ម ដើម្បីឱ្យដើមដងដុះលូតលាស់លឿន ។

### ៨.៣ ការកម្ចាត់ស្មៅចង្រៃ:

ពពួកស្មៅចង្រៃ ជាប្រភេទរុក្ខជាតិដែលដុះលូតលាស់សម្រាប់ប្រជែងជាមួយដំណាំដើម្បីដណ្តើមយកទីធ្លារ សារធាតុចិញ្ចឹម ពន្លឺ ទឹកពិសេសនៅរដូវមានភ្លៀងធ្លាក់ច្រើន និងបណ្តាលឱ្យទិន្នផលថយចុះ។

ការធ្វើស្មៅដំឡូងមី គួរចាប់ផ្តើមធ្វើក្នុងកំឡុងពេល២-៣ ខែក្រោយដាំ ការធ្វើស្មៅក្នុងកំឡុងពេលនេះធ្វើឱ្យទទួលបានទិន្នផលខ្ពស់។

#### ក. ផលប៉ះពាល់នៃការពន្យាពេលការធ្វើស្មៅ:

- ដំឡូងមីងាយទទួលរងការប្រកួតប្រជែងពីស្មៅពិសេសក្នុងដំណាក់កាលលូតលាស់ដំបូងពេលដំឡូងអាយុបាន១-៣ខែក្រោយដាំ
- នាំឱ្យទិន្នផលថយចុះ
- ទុកឱ្យស្មៅដុះលូតលាស់ប្រជែងជាមួយដំឡូងរហូត៦០ ថ្ងៃគិតចាប់តាំងពីដាំបណ្តាលឱ្យទិន្នផលថយចុះប្រហែល ៥០ %។

#### ខ.ពេលវេលាសមស្របក្នុងការធ្វើស្មៅ:

- ក្នុងកំឡុងពេល២ ខែដំបូងក្រោយដាំ យើងអាចធ្វើ២ - ៣ដង បើសិនជាចាំបាច់
- ការធ្វើស្មៅ៣ ខែក្រោយដាំធ្វើឱ្យទិន្នផលមើមថយចុះ
- ជាការប្រសើរគួធ្វើស្មៅក្នុងកំឡុងពេល៣ ឬ៤ អាទិត្យក្រោយដាំ និងអាចធ្វើម្តងទៀតនៅពេលស្លឹកដំឡូងដុះគ្របដីជិត។

### ៨.៤ វិធីសាស្ត្រទប់ស្កាត់ការហូរច្រោះ និងអត្ថប្រយោជន៍

#### ក. វិធីសាស្ត្រទប់ស្កាត់ការហូរច្រោះ

- ភ្ជួរដីជាជួរស្របទិសជម្រាល ហើយលើករងកាត់ទទឹង
- ការដាំដុះដោយប្រើប្រាស់កាកសំណល់ស្មៅរុក្ខជាតិដែលងាប់ឬប្លាស្ទិកដោយធ្វើការចោះរន្ធត្រង់ចំណុចគុម្ព ឬគល់ធ្វើជាគម្របដី
- ដាំពពួកស្មៅ ឬពពួកសណ្តែកធ្វើជារបងសម្រាប់ខណ្ឌ ឬជារបាំង

#### ខ. សារៈប្រយោជន៍ការទប់ស្កាត់ការហូរច្រោះ

- រក្សាបាននូវសារធាតុចិញ្ចឹម ដែលម្ចាស់ចម្ការបានផ្តល់ដូចជាជីលាមកសត្វ ជីស្រស់ ជីកំប៉ុស្ត និងជីគីមី
- មានភាពងាយស្រួលក្នុងការរៀបចំដី
- រក្សាបាននូវរចនាសម្ព័ន្ធដីឱ្យមានលក្ខណៈល្អប្រសើរ

## ៩. វិធានការណ៍ការពារកត្តាចង្រៃលើដំណាំដំឡូងមី

### ៩.១ វិធានការក្សេត្រសាស្ត្រ

វិធានការក្សេត្រសាស្ត្រ អាចអនុវត្តបានច្រើនវិធីដូចជាការជ្រើសរើសរដូវកាលដាំដុះ ការជ្រើសរើសពូជ ការរៀបចំដី និងមានវិធានការមួយចំនួនទៀតដូចជា៖

- កម្ទេចចោលចំពោះដើមណាដែលមានការបំផ្លាញពីពពួកសត្វល្អិតចង្រៃ
- បង្កើនចំនួនសត្វល្អិតមានប្រយោជន៍ដើម្បីកម្ចាត់សត្វល្អិតចង្រៃ
- មិនត្រូវនាំយកដើមដំឡូងមីដែលមានកើតជំងឺមកដាំក្នុងចម្ការ
- ដកដើមដែលមានការបំផ្លាញ ឬកើតជំងឺកម្ទេចចោល
- សម្អាតសម្ភារដាំដុះ ក្នុងសូលុយស្យុងទឹកអូសាវ៉ែលដើម្បីសម្លាប់មេរោគឱ្យអស់មុនប្រើប្រាស់
- ប្រើប្រាស់ពូជដែលមានភាពធន់ ទៅនឹងការបំផ្លាញ ពីពពួកសត្វ

ល្អិត និងជំងឺគ្រប់ប្រភេទ។

- ដាំដុះឱ្យមានចន្លោះរង និងចន្លោះជួរសមស្រប
- ដាំដុះផ្លាស់ប្តូរមុខដំណាំ ជៀសវាងការដាំដុះមុខដំណាំដដែលៗ លើផ្ទៃដីតែមួយ
- ធ្វើការសម្អាតស្មៅ និងរំលួសស្លឹកផ្នែកខាងក្រោមចោលខ្លះ ព្រោះ វាជម្រកពពួកសត្វល្អិតចង្រៃ។

## ៩.២ វិធានការគីមី

មានវត្តមានសត្វល្អិតចង្រៃជាច្រើនប្រភេទ ដែលតែងធ្វើការបំផ្លាញផលដំណាំរបស់ប្រជាកសិករជារៀងរាល់ឆ្នាំ ។ ដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយនេះ ប្រជាកសិករតែងប្រើប្រាស់គ្រប់វិធានការ ដើម្បីការពារផលដំណាំរបស់ខ្លួន ក្នុងនោះវិធានការក្សេត្រសាស្ត្រជាជម្រើសទី១ របស់ពួកគាត់ព្រោះជាវិធានការដែលមិនមានការចំណាយច្រើន ។

វិធានការទី២ គឺជាវិធានការគីមី ដែលវិធានការនេះ គឺជាវិធានការចុងក្រោយ នៅពេលដែលវិធានការក្សេត្រសាស្ត្រ មិនទទួលបានជោគជ័យ រាល់ការប្រើប្រាស់វិធានការគីមី ត្រូវតែមានការពិចារណាឱ្យបានល្អិតល្អន់មុនពេលសម្រេចថាត្រូវប្រើប្រាស់ថ្នាំគីមី ពិសេសត្រូវមានការប្រឹក្សាជាមួយអ្នកជំនាញកសិកម្ម ។

### ក. ជំងឺ

❁ **ជំងឺ Cassava Mosaic Disease :** បង្កឡើងដោយវីរុសដែលកើតមាននៅក្នុងស្លឹក និងដើមរបស់ដំឡូងមី។ ជំងឺនេះមានការប៉ះពាល់ធ្ងន់ធ្ងរដល់ការដុះលូតលាស់ដូចជា កម្ពស់ដើម ទំហំដើម ទំហំស្លឹក និងទិន្នផល។ ស្លឹកដែលរងការបំផ្លាញមានការបាត់បង់ពណ៌ ដោយសារមានពណ៌លាយគ្នាដូចជាពណ៌បៃតង លឿង និងស។ ពេលការបំផ្លាញមានកម្រិតធ្ងន់ធ្ងរ ស្លឹកប្រែ

ជារួមតូច ហើយចាប់ផ្តើមថយចុះរាល់ការលូតលាស់។

រោគសញ្ញា របស់ជំងឺនេះ ងាយសម្គាល់ បើសិនមានការរាតត្បាត លើដើមដំឡូងនៅតូច។ ប្រភពសំខាន់របស់វីរុសដែលបង្កឱ្យមានជំងឺនេះ គឺដើមដំឡូងមីដែលមានផ្ទុក



*ជំងឺ Cassava Mosaic Disease កើតលើស្លឹក*

ជំងឺ និងរុយស Bemisia tabaci។ វីរុសបំបែកខ្លួនយ៉ាងឆាប់រហ័សនៅក្នុងស្លឹក និងដើម។ ជំងឺនេះអាចរីករាលដាលតាមរយៈការដាំកំណាត់ដើមដែលមានផ្ទុកជំងឺ។

- **ជំងឺរលួយមើម (Root rot) :** ជំងឺនេះបង្កឡើងដោយពពួកផ្សិត Phytopthora ជំងឺការរាតត្បាតមានលក្ខណៈស្រួចស្រាវ និង ណ្ដាលឱ្យមានការបាត់បង់ទិន្នផលច្រើនជាង៥០% ។ ដើមហេតុ ដែលបណ្ដាលឱ្យកើតជំងឺនេះបណ្ដាលមកពីការស្រោចស្រពហួសកម្រិត ឬមួយក៏ការមានការអាក់ខាន ក្នុងការស្រោចស្រព។ ជំងឺនេះ



*ជំងឺរលួយមើម (Root rot) កើតលើមើម*

មិនមានរោគសញ្ញានៅផ្នែកខាងក្រៅទេ។ មើមដំឡូងដែលកើតជំងឺនេះ មានពណ៌ត្នោតលើកោសិកាផ្នែកខាងក្នុង ឬក៏រលួយ និងមានក្លិនស្អុយ។

❁ **ជំងឺ Cassava Brown steak diseases :** គឺជាជំងឺដែលបង្កឡើងដោយវីរុស Carlavirus វាកើតឡើងនៅលើស្លឹក ដើម និងមើម ។ នៅលើស្លឹកដែលមានកើតជំងឺនេះ មានស្នាមពណ៌លឿង លាយជាមួយពណ៌បៃតង ចំពោះដើមដែលកើតជំងឺនេះវិញ មានលេចចេញនូវស្នាមពណ៌ត្នោតចាស់ដែលមានរាងជាបន្ទះ នៅលើមើម ធ្វើឱ្យខូចទ្រង់ទ្រាយមើម និងមានការប្រែពណ៌នៅលើសម្បកមើម។



*ជំងឺ Cassava Brown steak diseases កើតលើស្លឹក*



*ជំងឺ Cassava Brown steak diseases កើតលើដើម*

❁ **ជំងឺអុចត្នោត ( Brown leaf spot ):** ជំងឺបង្កឡើងដោយ Cercospora henningsii ដែលធ្វើឱ្យដើមដំឡូងជ្រុះស្លឹកខ្លាំង។ ការរាលដាលរបស់ជំងឺអាស្រ័យលើកត្តាអាកាសធាតុការគ្រប់គ្រងសារធាតុចិញ្ចឹម និងពូជ។



*ជំងឺអុចត្នោត ( Brown leaf spot ) កើតលើស្លឹក*

### ❁ ជម្ងឺរលួយឫស:

ជំងឺនេះបង្កឡើងដោយពពួកផ្សិត ដោយវាវាត្បាតទៅលើប្រព័ន្ធឫស ដែលស្ថិតនៅក្នុងដី ហើយធ្វើឱ្យរលួយភាគច្រើននៅក្នុងរដូវភ្លៀង និងលើដីកណ្តៀងជាំទឹក ព្រមទាំងមានជីធម្មជាតិច្រើន ។ រោគសញ្ញាជំងឺនេះ វាធ្វើឱ្យដើមដងស្រពោន ងាប់បន្តិចៗម្តង ថែមទាំងបញ្ចេញសារធាតុទឹកម៉្យាងដែលមានក្លិនស្អុយបន្ទាប់មកប្រព័ន្ធឫសចាប់ផ្តើមរលួយ ។

គេអាចជៀសវាងជំងឺនេះបាន តាមរយៈការជ្រើសរើសដីដែលមានលក្ខណៈសមស្រប គឺដីមិនជាំទឹក ។

### ❁ ជំងឺរលួយដើមដោយបាក់តេរី

ដំឡូងមីដែលទទួលរងនូវជំងឺប្រភេទនេះ គេអាចសង្កេតឃើញនៅលើត្រួយ ឬពន្លកថ្មីរបស់វាក្រៀមស្ងួត ហើយមានសភាពរលួយមើមនៅលើដងដើម នៅលើផ្ទៃ នៃដងដើម គេសង្កេតឃើញ មានរន្ធតូចៗពាសពេញរន្ធទាំងនោះ មានលក្ខណៈពិសេសមួយ ដែលងាយស្រួលក្នុងការកំណត់ចំណាំ គឺគេឃើញមានជ័រស្ងួត។ ពេលដែលគេកាត់ដើម ដែលមានជំងឺនេះមានលក្ខណៈក្រិនទាប និងប្រព័ន្ធឫសលូតលាស់ខ្សោយបំផុតគេអាចជៀសវាងបញ្ហានេះបាន ដោយគ្រាន់តែជ្រើសរើសដើមណាដែលមានសុខភាពល្អយកទៅធ្វើពូជ ឬជ្រើសរើសយកពូជធន់នឹងជំងឺនេះ។

### ❁ ជំងឺខ្លោចស្លឹកបង្កដោយ Choenophora cucuritarium

រោគសញ្ញានៃជំងឺនេះ គឺបង្ហាញឱ្យឃើញនូវស្នាមអុចៗ ខ្លោចធំៗនៅលើស្លឹក ពេលមានជំងឺប្រភេទនេះកើតលើស្លឹក ធ្វើឱ្យបាត់បង់ពណ៌បៃតងស្រអាប់ ហើយលេចឡើងនូវផ្សិតម្សៅពណ៌សប្រផេះ។ នៅពេលព្រឹកព្រលឹមផ្សិតម្សៅនេះរលាយបន្តិចម្តងៗ នៅពេលមានសីតុណ្ហភាព

ឡើងក្តៅ។ លើផ្ទៃស្លឹកផ្នែកខាងក្រោមគេសង្កេតសរីរាង្គផ្សិតនោះមានការលូតលាស់ពីមួយថ្ងៃទៅមួយថ្ងៃ ។ បន្ទាប់មកដំឡូងមានសភាពស្ងួត ហើយក៏ជ្រុះធ្លាក់ទៅលើដី។ ជំងឺនេះដែរច្រើនរាតត្បាតនៅក្នុងខែឧសភា រហូតដល់ខែមិថុនា។

### វិធានការការពារ និងទប់ស្កាត់ជំងឺលើដំឡូងមី

- ប្រើប្រាស់សម្ភារដាំដុះដែលគ្មានកើតជំងឺ
- ប្រើពូជធន់ទ្រាំនឹងជំងឺ
- ជ្រើសរើសប្រភេទដីមិនដក់ទឹក
- បង្កើតប្រព័ន្ធបង្ហូរទឹក
- ដាំដំណាំលើរង
- ដាំដំណាំឆ្លាស់

ឤ.ឯ.ឯ.ឯ AIDOC
Code:
Date:
Donated by:

## ខ. សត្វល្អិតចង្រៃ

- ចៃ (Aphids) ឈ្មោះវិទ្យាសាស្ត្រ : Aphis gosspii គ្រួសារ: Homoptera Aphididae

**រោគសញ្ញា:** សត្វល្អិតប្រភេទនេះ តែងបំផ្លាញប្រព័ន្ធឫស ខ្លួនមានទំហំតូចពណ៌លឿង បៃតង ឬខ្មៅ ហើយមានក្បាលតូច។ វាមានខ្លួនទន់ធ្វើចលនាយឺតៗធ្វើការបំផ្លាញគ្រប់ដំណាក់កាលលូតលាស់ ដោយបឺតយករុក្ខរសពីស្លឹក ដើម និងចំណុចលូតលាស់ផ្សេងទៀត។ ពេលមានការបំផ្លាញធ្ងន់ធ្ងរកូនដំឡូងចាប់ផ្តើមចុះខ្សោយ ហើយបន្ទាប់មកងាប់តែម្តង។ ស្លឹកដែលទទួលរងការបំផ្លាញមានសភាពរួញប្រែជាពណ៌ត្នោត បន្ទាប់ងាប់។

ចៃ វាបឺតយករុក្ខរសពីដើមដំឡូង ហើយបន្សល់ទុកសារជាតិទឹកដមដែលជាហេតុធ្វើឱ្យមានការទាក់ទាញ ដល់សត្វស្រមោចមករោម និងធ្វើការបំផ្លាញនៅទីកន្លែងនោះផងដែរ។ ក្នុងមួយវដ្តជីវិតរបស់ចៃ មានរយៈ

ពេលពី២១-២៨ ថ្ងៃ។



*ចៃ (Aphids) ពេញវ័យ*

### វិធានការការពារ និងកម្ចាត់:

- បង្កើតពពួកប្រេដាទ័រពីធម្មជាតិ ដូចជាពពួកអណ្ដើកមាស ព្រោះអណ្ដើកមាសវាស៊ីចៃ
- អាចប្រើថ្នាំគីមីដូចជាពពួក Fastac, Decis ឬ Karate ក្នុងកម្រិត ៦ ម.ល លាយជាមួយទឹក៤៥០០ ម.ល ឬ ប្រើពពួក Sevin 85 % W.P. (Cabarye) ក្នុងកម្រិត ៦ ម.ក្រ លាយជាមួយទឹក ៤៥០០ ម.ល ឬក៏ពពួក Malathion 57 E.C ក្នុងកម្រិត ១៥ ម.ល លាយជាមួយទឹក ៤៥០០ ម.ល ដោយបាញ់ឱ្យចំផ្ទៃស្លឹក។

### ចំណាំ:

- បើបាញ់ថ្នាំប្រភេទ Sevin ឬ Malathion ត្រូវរង់ចាំពី ៧-១០ ថ្ងៃទើបធ្វើការប្រមូលផល
- បើបាញ់ថ្នាំប្រភេទ Fastac, Decis ឬ Karate ត្រូវរង់ចាំពី ៣-៥ ថ្ងៃ

ទើបធ្វើការប្រមូលផល។

❁ រុយស ( White fly ) ឈ្មោះវិទ្យាសាស្ត្រ : Bemisia tabaci

គ្រួសារ : Homoptera Aleyrodidae

លក្ខណៈរូបសាស្ត្រនិងរោគសញ្ញា: រុយសពេលពេញវ័យមានដងខ្លួនប្រវែង ២ ម.ម និងស្លាបរបស់វាត្រូវបានគ្របដណ្តប់ដោយម្សៅពណ៌ស។ ក្បាលកូនដង្កូវមានសភាពរាបស្មើ និងស្ថិតនៅជាប់ផ្ទៃស្លឹក ផ្នែកខាងក្រោមរហូតដល់ពេញវ័យ។

ដង្កូវ និងសត្វពេញវ័យរស់នៅបាន ដោយសារបឺតជញ្ជក់រុក្ខរសពីដំឡូងមី ធ្វើឱ្យរាំងស្ទះដល់ដំណើរការធ្វើរស្មីសំយោគ និងបានបន្សល់ទុកនូវសារជាតិទឹកដមនៅលើស្លឹកដែលជាមូលហេតុធ្វើឱ្យមានការទាក់ទាញដល់ពពួកស្រមោចមកមន្ថែមនូវការបំផ្លាញមួយកម្រិតទៀត។ មិនតែប៉ុណ្ណោះ រុយស គឺជាភ្នាក់ងារចម្លងជំងឺផងដែរ។

វដ្តជីវិតរុយសមានរយៈពេលពី ២៨-៣៥ ថ្ងៃ។



*រុយស ( White fly ) ពេញវ័យ*

### វិធានការការពារ និងកម្ចាត់:

- ជៀសវាងការដាំដំណាំថ្មី នៅជិតចម្ការដែលមានដំណាំធំហើយ ធ្វើបែបនេះអាចជួយបង្អាក់នូវវដ្តជីវិតរបស់រុយសបាន

- ប្រើប្រាស់វិធានការចម្រុះការពារដំណាំ
- សម្អាតចម្ការជាប្រចាំ ព្រោះស្មៅ ឬ រុក្ខជាតិមិនមានប្រយោជន៍ជាជម្រករបស់សត្វល្អិតចង្រៃ
- ប្រើថ្នាំគីមី ដូចជាពពួក Admire, Pegasus និង Basudin/ Vydate L ក្នុងកម្រិត ១០ ម.ល លាយទឹក ៤៥០០ ម.ល
- ប្រើផលិតផល មានសណ្ឋានជាសាប៊ូ ដូចជា Soap based products សំដៅកម្ចាត់ទាំងកូនដង្កូវ និង រុយសពេញនៅពេលព្រឹកព្រលឹម។

**ចៃស (Mealy bug)** ឈ្មោះវិទ្យាសាស្ត្រ : Phenococcus គ្រួសារ : Homoptera Pseudococcidae

**រោគសញ្ញា:**

រាល់ការបំផ្លាញរបស់សត្វល្អិតប្រភេទនេះ តែងធ្វើឱ្យដំឡូងជ្រុះស្លឹក និងធ្វើឱ្យដើមដំឡូងចុះខ្សោយ។ សភាពដើមទាំងមូលមានជំងឺងាប់ចុង។ ឬ ក្រិន លើស្លឹកមានពណ៌ខុសប្រក្រតី ខូចទម្រង់ ជ្រុះស្លឹកខុសពីធម្មតា ស្រពោន ហើយប្រែជាពណ៌លឿង រមូរស្លឹកចូលគ្នា និងងាប់ស្លឹក។ ដើមមានសភាព



*ចៃស (Mealy bug) ពេញវ័យ និងការបំផ្លាញ*

គ្រិន ងាប់ផ្នែកខាងចុងឫស និង ចុះខ្សោយគ្រប់សរីរាង្គលូតលាស់ពោលគឺមានជំងឺងាប់ត្រួយ។

**វិធានការការពារ និងកម្ចាត់:**

- ត្រូវមានវិធានការចម្រុះថែទាំដំណាំ(IPM)
- សម្អាតស្មៅ និង រុក្ខជាតិមិនមានប្រយោជន៍ក្នុងចម្ការជាប្រចាំធ្វើបែបនេះ ដើម្បីមិនឱ្យពពួកសត្វល្អិតចង្រៃមិនអាចតាំងជម្រកបាន
- ព្យាយាមដាំដំណាំបង្វិល
- ប្រើប្រាស់ពពួកសត្វដែលជា សត្រូវធម្មជាតិ ដូចជាពពួកប្រែដាទ័រ និងប៉ារ៉ាស៊ីតជាដើម។

❁ **ទ្រីប (Thrips)** ឈ្មោះវិទ្យាសាស្ត្រ : Frankliniella williamsi

គ្រួសារ : (Thysanoptera Thripidae

**រោគសញ្ញា:** ការបំផ្លាញមានលក្ខណៈស្រួចស្រាវ នៅក្នុងរដូវក្តៅ ពពួកទ្រីបបឺតយករុក្ខរសពីស្លឹក និង ធ្វើឱ្យស្លឹកទាំងនោះបាត់បង់ពណ៌។ ពេលដែលមានការបំផ្លាញស្លឹកដំឡូង មានសភាពគ្រិនកោសិកាចាស់ៗឈប់ដំណើរការ រួមទាំងការធ្វើរស្មីសំយោគផងដែរ។ វដ្តជីវិតរបស់ទ្រីបមានរយៈពេលពី១៤-២១ ថ្ងៃ។



*ទ្រីប (Thrips) ពេញវ័យ*



*ការបំផ្លាញរបស់ទ្រីបលើស្លឹក*

### វិធានការការពារ និងកម្ចាត់:

- ត្រូវធ្វើការសម្អាតស្មៅជាប្រចាំ
- កម្ចាត់ចោលនូវកាកសំណល់ពីរដូវមុនពីចម្ការ
- ដាំដុះដំណាំបង្វិល
- ជៀសវាងការដាំដំណាំជាជម្រកសត្វល្អិតប្រភេទនេះ
- ការស្រោចស្រពក៏ជាមធ្យោបាយមួយសម្រាប់កម្ចាត់ទ្រីបបានមួយកម្រិតដែរនៅរដូវក្ដៅ
- ប្រើប្រាស់វិធានការចម្រុះថែទាំដំណាំ( IPM )
- បាញ់ថ្នាំ Regent ( Fipronil ), Admire, Abamectin និង Vy-date L ក្នុងកម្រិត ៥ ម.ល លាយជាមួយទឹក ៤៥០០ ម.ល បាញ់លើផ្ទៃស្លឹក និងផ្នែកខាងក្រោមស្លឹក។

## ១០. ការប្រមូលផល

- ដំឡូងមីអាចប្រមូលផលបានពេញ ១ ឆ្នាំ
- ការប្រមូលផលដំឡូងមីអាយុតិចជាងនេះធ្វើឱ្យទិន្នផលធ្លាក់ចុះ
- ចំពោះការដាំជាលក្ខណៈគ្រួសារ ការប្រមូលផលអាចធ្វើទៅតាមតម្រូវការជាក់ស្ដែង
- គួរប្រមូលផលនៅរដូវប្រាំង ព្រោះដំឡូងមានកម្រិតជាតិម្សៅល្អ មានតម្លៃខ្ពស់ និងមានតម្រូវការច្រើននៅលើទីផ្សារ
- ការប្រមូលផលនៅរដូវវស្សាដំឡូងមានកម្រិតជាតិម្សៅតិច មានតម្លៃថោក មានតម្រូវការទីផ្សារទាប ពិបាកសម្ងួត
- ដំឡូងអាយុចាប់ពី៨ ទៅ ១៤ ខែ អាចធ្វើការប្រមូលផលបាន
- ជាការប្រសើរគួរប្រមូលផលពេលដែលដំឡូងមានអាយុ១២ ខែ





- ការពន្យាពេលធ្វើការប្រមូលផលអាចធ្វើឱ្យកម្រិតជាតិម្សៅរបស់មើមមានការថយចុះ និងកើនឡើងសសៃ រឹងដូចឈើ។

ការប្រមូលផលដំឡូងអាចធ្វើទៅបានក៏អាស្រ័យទៅតាមពេវេលានៃការដាំដុះ ប្រភេទពូជ កត្តាអាកាសធាតុ ដី ពិសេសតម្រូវការទីផ្សារ។

ដំណាំដំឡូងឈើពូជស្រាល អាចប្រមូលផលបានក្នុងរយៈពេលពី ៥-៦ខែក្រោយពេលដាំ ។ លក្ខណៈសម្គាល់ គឺស្លឹកវាឡើងពណ៌លឿង ហើយចាប់ផ្តើមជ្រុះស្លឹកនៅគល់ ដេញឡើងទៅលើ ។ មុនគាស់មើមត្រូវកាប់ដើមចេញសិន ដោយទុកប្រហែល ៣០-៤០ ស.ម ពីដី ។

ចំពោះដំឡូងមីពូជធ្ងន់ អាចប្រមូលផលបានក្នុងរយៈពេល ១ ឆ្នាំ ឬលើសពី១ឆ្នាំ ។ ការប្រមូលផលអាចប្រែប្រួល ទៅតាមប្រភេទពូជ និងសេចក្តីត្រូវការរបស់អ្នកដាំ ។

**កំណត់សម្គាល់ ៖**

ការប្រមូលផលសម្រាប់បំរើការហូបចុក អាចធ្វើទៅបានចាប់តាំងពីមើមដំឡូងនៅខ្ចី រហូតដល់ចាស់ ។ ប៉ុន្តែសម្រាប់ បម្រើនៅក្នុងរោងចក្រឧស្សាហកម្មវិញ ត្រូវទុកមើមឱ្យចាស់គ្រប់អាយុពេញលេញទើបប្រមូលផល ដើម្បីបង្កើនជាតិម្សៅបានច្រើន ។

## ការទុកដាក់មើមដំឡូង ៖

មើមដំឡូងឈើ ជាទូទៅគឺមិនអាចធានាទុកបានយូរពេកទេ ពីព្រោះវាងាយរលួយខូចណាស់ ការដែលឆាប់រលួយបែបនេះគឺបណ្ដាលមកពីមេរោគ និងជំងឺផ្សេងៗ ។ គេអាចជៀងវាងចំពោះការដែលបណ្ដាលឱ្យរលួយនេះបានដោយយើងត្រូវរក្សាមើមដំឡូងនោះ ដោយកប់មើមដំឡូងទៅក្នុងដី ឬខ្សាច់ ឬក៏អាចដាក់ក្នុងបាវ ឬក្រដាស់សើម ។

គេអាចរក្សាទុកមើមដំឡូងក្នុងរយៈពេលយូរបាន ដោយទុកវានៅក្នុងទូ ឬបន្ទប់ត្រជាក់ដែលមានសីតុណ្ហភាពត្រឹម ២៥ អង្សាសេ ។

វិធីទុកដាក់ម៉្យាងទៀត គឺគេចិតមើមដំឡូងនោះស្ដើងៗ ហាលថ្ងៃឱ្យស្ងួតរហូតដល់សំណើមក្នុងមើមដំឡូងនោះនៅត្រឹម១០-១២ភាគរយប៉ុណ្ណោះ។ គេអាចបន្ថយនៅការរលួយមើមបានមួយកម្រិតតាមរយៈការកប់ដើមចោលមុនពេលប្រមូលផលប្រមាណពី ៧-១១ ថ្ងៃ ។ ការទុកដាក់ដោយខ្ចប់ក្រដាសសើម គឺអាចបន្ថយភាពរលួយបានមួយកម្រិត បើក្នុងករណីដែលគេត្រូវនាំចេញមើមស្រស់ទៅលក់នៅកន្លែងឆ្ងាយ ឬ បរទេស គេត្រូវតែប្រមូលផលនៅពេលដែលដំឡូងមានអាយុមិនលើសពី ១០ ខែ បន្ទាប់ពីដាំ ។





## ឧបករណ៍សម្រាប់ធ្វើការប្រមូលផល

- ចប ( ចប់ជីក ចបកាប់ )
- កាំបិត
- កណ្ដៀវ
- គ្រឿងចក្រសម្រាប់ការដាំជាលក្ខណៈឧស្សាហកម្ម

## គុណប្រយោជន៍មើមដំឡូងមីផ្នែកអាហាររូបត្ថម្ភ

មើមដំឡូងសម្បូរទៅដោយជាតិម្សៅ ដែលអាចឱ្យអ្នកបរិភោគទទួលបាននូវរបបអាហារទ្រទ្រង់រាងកាយពិសេសសម្រាប់ដល់កុមារ មិនតែប៉ុណ្ណោះមើមដំឡូងមីគេអាចយកវាទៅធ្វើជាចំណីសត្វ ហើយម្សៅដំឡូងគេអាចយកទៅធ្វើជានំប័ុងជំនួសស្រូវសាឡីបាន ជាវត្ថុធាតុដើម សម្រាប់រោងចក្រក្នុងផលិតជាក្រដាស់ ជាពិសេសអាចកែច្នៃធ្វើជាគ្រាប់សាគូ និងមុខរណាសម្រាប់ធ្វើជាបង្អែមយ៉ាងឆ្ងាញ់ពិសារ៕

## ឯកសារយោង:


១. ដំណាំដំឡូងមី នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម, ២០០៣

២. ប្រសិទ្ធភាពជីប៉ូតាស្យូមទៅលើទិន្នផលដំឡូងមីពូជខុសគ្នាក្នុងលក្ខខណ្ឌដីល្បាយខ្សាច់ មឹង បុប្ផាយ៉ានីកា, ២០១១

៣. ប្រសិទ្ធភាពបច្ចេកទេសដាំដុះលើទិន្នផលនៃពូជដំឡូងKM 94 យូ អឹម,២០១១

៤. ឥទ្ធិពលរយៈពេលដាំដុះទៅលើការដុះលូតលាស់របស់ពូជដំឡូងមី KM 94, ២០១៤

៥. ការអនុវត្តការដាំដុះដំណាំដំឡូងមី ( CIAT-cambodia ) ខេត្តបាត់ដំបង, ២០១៤




**អាសយដ្ឋាន** : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចម្ការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : (០២៣) ២១៥ ៨១៩/០១២ ៨៣ ៧៩ ៤៥

**ទូរសារលេខ** : (៨៥៥)២៣ ២១០ ៩៤៨

**Facebook** : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម - **Department of Agricultural Extension**

**គេហទំព័រ** : **http://www.maff.gov.kh**